សហភាពអឺរ៉ុប

ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩

# សេចក្តីប្រកាសព័ត៌មាន

**ពិធីបិទ"កម្មវិធីវិស័យជលផល និងផលិតកម្មបសុសត្វឆ្នាំ២០១៣-ឆ្នាំ២០១៨" និងពិធីប្រកាសដាក់ឱ្យអនុវត្ត "កម្មវិធីអភិវឌ្ឍន៍វិស័យជលផលឆ្នាំ២០១៩-ឆ្នាំ២០២៣" កម្មវិធីទាំងពីរត្រូវបានផ្តល់ជំនួយហិរញ្ញប្បទានឥតសំណងពីសហភាពអឺរ៉ុប**

ប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំ**ពិធីបិទកម្មវិធី** "ជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្ន នៃអនុវិស័យជលផល និងផលិតកម្មបសុសត្វ" និង**ពិធីសម្ពោធកម្មវិធីអភិវឌ្ឍន៍វិស័យជលផល ក្រោមជំនួយថវិកាថ្មីពីសហភាពអឺរ៉ុប** នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩។

ចាប់ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ សហភាពអឺរ៉ុប បានឧបត្ថម្ភថវិកាជំនួយឥតសំណងចំនួន ២០ លាន អឺរ៉ូ លើ**កម្មវិធី "ជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្ន នៃអនុវិស័យជលផល និងផលិតកម្មបសុសត្វ**"គ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ កម្មវិធីនេះមានបីផ្នែកដែលស្ថិតនៅក្រោមការអនុវត្តផ្ទាល់របស់នាយកដ្ឋានផែនការ និងស្ថិតិ រដ្ឋបាលជលផល និងអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

គោលបំណងនៃកម្មវិធីនេះ គឺដើម្បីធានាថា អនុវិស័យជលផល និងបសុសត្វ ទទួលបានកំណើនប្រកបដោយភាពស្មើគ្នា បរិយាប័ន្ន មិនធ្វើឲខូចខាតដល់បរិស្ថាន និងប្រកបដោយចីរភាព ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋជនបទទាំងអស់នៅក្នុងប្រទេសកម្ពុជា។ គ្រប់សកម្មភាពនៃកម្មវិធីនេះបានជួយលើកកម្ពស់ចីរភាពនៃធនធានជលផល និងបសុសត្វ តាមរយៈការជំរុញឱ្យមានការចូលរួមសហការគ្នាពីអាជ្ញាធរថ្នាក់ជាតិ អាជ្ញាធរមូលដ្ឋាន សហគមន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន។

កម្មវិធីនេះបានជួយគាំទ្រដល់ការបង្កើតគោលនយោបាយកសិកម្មថ្នាក់ជាតិ និងជួយពង្រឹងសមត្ថភាពកិច្ចការរដ្ឋបាល និងបុគ្គលិករាប់ពាន់នាក់ គ្រប់កម្រិតនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងជួយបង្កើតទំនាក់ទំនង និងបណ្តាញកាន់តែល្អប្រសើររវាងប្រជាកសិករ ជាមួយនឹងពាណិជ្ជករ និងមន្ត្រីក្រសួង ហើយក៏ជួយគាំទ្រដល់ការស្រាវជ្រាវ និងការអភិវឌ្ឍដើម្បីប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ និងគ្រប់គ្រងបសុសត្វឱ្យកាន់តែល្អប្រសើរ។ កិច្ចខិតខំប្រឹងប្រែងនានាក្រោមជំនួយថវិកាពីសហភាពអឺរ៉ុប នាំឱ្យមានការផ្ទេរជំនាញ និងចំណេះដឹងសំខាន់ៗពីក្រសួងកសិកម្មនៅថ្នាក់ជាតិទៅសហគមន៍នេសាទ និងប្រជាកសិករក្នុងការចិញ្ចឹមសត្វ ឬវារីវប្បកម្ម ដោយជួយពង្រឹងការអនុវត្ត និងលើកស្ទួយជីវភាពពួកគាត់។

នៅក្នុងអំឡុងពេលអនុវត្តកម្មវិធីក្រោមជំនួយថវិកាពីសហភាពអឺរ៉ុបនេះ ផលិតកម្មវារីវប្បកម្មបានកើនឡើងគួរឱ្យកត់សម្គាល់ពី ៩ ម៉ឺន តោននៅឆ្នាំ ២០១៣ រហូតដល់ ២៥ ម៉ឺន តោននៅឆ្នាំ២០១៨ ហើយការនេសាទត្រីទទួលបាន

ទិន្នផលប្រហែល ៦០ ម៉ឺនតោន(ឆ្នាំ២០១៨)។ សមិទ្ធផលដ៏សំខាន់មួយគឺការពង្រឹងសហគមន៍នេសាទ រួមមានការអភិរក្សជម្រកមច្ឆជាតិសំខាន់ៗ និងការបង្កើតជម្រកមច្ឆជាតិនៅតាមសហគមន៍។ ទន្ទឹមគ្នានេះ ច្បាប់ជលផល ត្រូវបានធ្វើវិសោធនកម្ម ហើយផែនការសកម្មភាពសម្រាប់វិស័យជលផល ក៏ត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីប្រយុទ្ធប្រឆាំងឱ្យកាន់តែមានប្រសិទ្ធភាពលើការនេសាទខុសច្បាប់ ការនេសាទដោយគ្មានការអនុញ្ញាត និងគ្មានរបាយការណ៍។ ការបណ្តុះបណ្តាលនានាបានផ្តល់ជាប្រយោជន៍ដល់មន្ត្រីជាប់ពាក់ព័ន្ធមកពីរដ្ឋបាលជលផល សិស្សនិស្សិត សហគមន៍ និងភាគីពាក់ព័ន្ធផ្សេងទៀតនៅក្នុងផ្នែកវារីវប្បកម្ម។

កម្មវិធីផ្នែកផលិតកម្មសត្វ ត្រូវបានអនុវត្តនៅក្នុងខេត្ត-ក្រុងចំនួន ២៥។ បុគ្គលិកថ្នាក់ជាតិ និងខេត្តចំនួន ៦ ៦៤៧ នាក់នៅអគ្គនាយកដ្ឋាននិងមន្ទីរសុខភាពសត្វ និងផលិតកម្មសត្វ បានទទួលការបណ្តុះបណ្តាលលើជំនាញជាច្រើនរាប់ចាប់ពីការរៀបចំផែនការ និងការតាមដានយុទ្ធសាស្ត្រ រហូតដល់ការគ្រប់គ្រងជំងឺសត្វ និងទីសត្តឃាតដ្ឋាន និងជំនាញបង្កាត់គោក្របី និងជ្រូកដោយសិប្បនិម្មិត។ កម្មវិធីនេះក៏បានជួយគាំទ្រការបង្កើតកម្មវិធីសិក្សាវិទ្យាសាស្ត្របសុពេទ្យ និងសេចក្តីព្រៀងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាបសុពេទ្យថ្នាក់ជាតិ។ បុគ្គលិកសុខភាពសត្វតាមភូមិចំនួនប្រហែល ៣ ៨០៥ នាក់ និងអ្នកចិញ្ចឹមសត្វខ្នាតតូចចំនួន ១៨ ៨៣៤ នាក់ បានទទួលប្រយោជន៍ដោយផ្ទាល់ពីកម្មវិធីនេះ។ ទន្ទឹមគ្នានេះដែរ តាមការប៉ាន់ស្មាន ការផលិតបសុសត្វនៅក្នុងប្រទេសកម្ពុជា បានកើនឡើងពី ៣៧,៩ លានក្បាលនៅឆ្នាំ ២០១៤ ដល់ ៤៤, ៣ លានក្បាលនៅឆ្នាំ២០១៨។

## កម្មវិធីអភិវឌ្ឍន៍វិស័យជលផល ក្រោមជំនួយហិរញ្ញប្បទានឥតសំណងថ្មីពីសហភាពអឺរ៉ុប

សហភាពអឺរ៉ុបបានអនុម័តកម្មវិធីថ្មីឈ្មោះថា "កម្មវិធីអភិវឌ្ឍន៍វិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា" ក្រោមជំនួយថវិកាសរុបចំនួន ១១២ លានអឺរ៉ូ អនុវត្តពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ដែលនឹងបន្តពង្រីកឱ្យបានកាន់ច្រើនខ្លាំងថែមទៀតលើសកម្មភាពស្ថិតក្រោមផ្នែកជលផលនៃសកម្មភាពពីមុន ដើម្បីដោះស្រាយបញ្ហាប្រឈមនានានៅក្នុងអនុវិស័យនេះ។ កម្មវិធីថ្មីនេះមានគោលដៅបង្កើនសន្តិសុខស្បៀង ពង្រឹងអាហារូបត្ថម្ភ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចថែមទៀត។ កម្មវិធីនេះគឺជាកម្មវិធីជំនួយថវិកាឥតសំណងធំបំផុតរបស់សហភាពអឺរ៉ុបប្រចាំនៅកម្ពុជា ហើយមានសកម្មភាពពីរផ្នែករួមគ្នា គឺវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផល។

- ផ្នែកគ្រប់គ្រងធនធានជលផល **(CAPFISH-Capture)** ក្រោមជំនួយថវិកាចំនួន ៨៧ លានអឺរ៉ូ មានគោលបំណងជានាធនធានជលផលទឹកសាប និងសមុទ្ររបស់ប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រង និងអភិវឌ្ឍប្រកបដោយចីរភាព អាចបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងប្រកបដោយបរិយាប័ន្ន។ កម្មវិធីនេះផ្តោតជាពិសេសលើការគ្រប់គ្រងធនធានជលផលប្រកបដោយចីរភាពនៅបឹងទន្លេសាប និងធនធានសមុទ្រ។ កម្មវិធីនេះចាប់ផ្តើមសម្ពោធនៅថ្ងៃនេះ។ ក្រៅពីរាជរដ្ឋាភិបាលកម្ពុជា(ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលជលផល) កម្មវិធីនេះនឹងអនុវត្តដោយអង្គការស្បៀង និង កសិកម្មសហប្រជាជាតិ(FAO) អង្គការយូនេស្កូ(UNESCO) និងយូនីដូ(UNIDO) ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀតដែលនឹងត្រូវជ្រើសរើសតាមរយៈការប្រកាសឱ្យដាក់សំណើសុំ។

- ផ្នែកវារីវប្បកម្ម ក្រោមជំនួយថវិកាចំនួន ២៥ លានអឺរ៉ូ មានបំណងបង្កើនទិន្នផលមច្ឆជាតិ ដំណើរការស្របគ្នានឹងផ្នែកគ្រប់គ្រងធនធានជលផល **(CAPFISH-Capture)** ដែរ ត្រូវអនុវត្តរយៈពេលជាង ៧២ ខែ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ កម្មវិធីនេះអនុវត្តដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង(AFD)។

**ឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា**មានប្រសាសន៍ថា "ក្នុងនាមជាដៃគូអភិវឌ្ឍន៍រយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា សហភាពអឺរ៉ុប មានសេចក្ដីរីករាយយ៉ាងខ្លាំងដែលឃើញជំនួយរបស់សហភាពអឺរ៉ុប បានចូលរួមចំណែកដល់វឌ្ឍនភាពនៃវិស័យជលផល និងផលិតកម្មបសុសត្វនៅប្រទេសកម្ពុជា ដោយវាបានផ្ដល់ប្រយោជន៍ដល់កសិករខ្នាតតូចជាច្រើននាក់នៅទូទាំងប្រទេសកម្ពុជា។ ខ្ញុំក៏រីករាយផងដែរដែលបញ្ញាប្រឈម និងបទពិសោធន៍នានាដែលទទួលបានពីកម្មវិធីដែលបានបញ្ចប់នេះនិងផ្ដល់ជាអនុសាសន៍ដ៏សំខាន់ដើម្បីអនុវត្តកម្មវិធីអភិវឌ្ឍន៍ វិស័យជលផលថ្មីខាងមុខនេះ"។

"សហភាពអឺរ៉ុបជឿជាក់ថា ជំនួយថវិកាបន្ថែមលើវិស័យជលផលនេះ នឹងជួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ រួមមានសហគមន៍នេសាទក្នុងប្រទេសកម្ពុជា ដើម្បីអាចគ្រប់គ្រងធនធានជលផលទឹកសាប និងសមុទ្ររបស់ប្រទេសកម្ពុជា កាន់តែមានប្រសិទ្ធផលដែលជាប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងមូល និងអ្នកជំនាន់ក្រោយ។ សហភាពអឺរ៉ុប ចង់ឃើញប្រជាជនកម្ពុជាទទួលបានប្រយោជន៍ដោយស្មើភាពគ្នា និង ចីរភាពពីធនធានដ៏អស្ចារ្យនៃបឹងទន្លេសាប និងសមុទ្រ ដែលសព្វថ្ងៃនេះកំពុងមានហានិភ័យក្នុងការបាត់បង់"។

**ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** មានប្រសាសន៍ថា "ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមវាយតម្លៃខ្ពស់លើកិច្ចខិតខំប្រឹងប្រែងរបស់សហភាពអឺរ៉ុបក្នុងការផ្ដល់ថវិកាជំនួយឥតសំណងដល់វិស័យជលផល និងផលិតកម្មបសុសត្វនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះដើម្បីគាំទ្ររាជរដ្ឋាភិបាលកម្ពុជា កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចដល់ប្រជាជនកម្ពុជា"។

**ឯកឧត្តម វេង សាខុន** មានប្រសាសន៍បន្ថែមទៀតថា "ការបន្តកិច្ចសហការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនឹងសហភាពអឺរ៉ុប ក្រោមកម្មវិធីជលផលថ្មីក្នុងរយៈពេលប្រាំឆ្នាំខាងមុខនេះ នឹងផ្ដល់សមិទ្ធផលរយៈពេលខ្លី និងរយៈពេលវែងកាន់តែល្អប្រសើរដល់ប្រជាសិករ វិស័យឯកជន និងអ្នកប្រើប្រាស់ផលិតផលជលផល។ រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់តួនាទីវិស័យជលផលបានចូលរួមចំណែកដល់ការអភិវឌ្ឍជាតិនៅប្រទេសកម្ពុជា ហើយវិស័យនេះបានជួយជានាឲប្រជាជនកម្ពុជា មានជីវភាពកាន់តែល្អប្រសើរ និងអាចទទួលទាននូវធនធានពីទឹកសាប និងសមុទ្ររបស់យើង គឺមានដូចជាត្រី មឹក បង្គា បង្កង និងក្ដាម ប្រកបដោយឱជារសដ៏ពិសេសនិងមិនអាចបំភ្លេចបាន"។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**


ប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា
លោកស្រី ពូន ប៉ុក
មន្ត្រីព័ត៌មាន
*អ៊ីមែល៖*Pok.POUN@eeas.europa.eu
*ទូរស័ព្ទ៖ (៨៥៥) ១២ ៣៤៧ ៧១៦*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
លោក ម៉ក់ ម៉ូនី
ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ
*អ៊ីមែល៖* makmony.maff@gmail.com
*ទូរស័ព្ទ៖ (៨៥៥)០៩២ ៥៩៩ ៣៣៦*